២០១៨

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

Ministry of Industry & Handicraft

លេខៈ ៤៣០១ MIH / ២០១៨

## ញត្តិគាំទ្រ

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម យើងខ្ញុំសូមសម្ដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះគោលជំហរយ៉ាងម៉ឺងម៉ាត់ប្រកបដោយភាពប្រាកដនិយម និងឧត្តមគតិជាតិបំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងបញ្ជាក់ «អំពីការមិនដោះដូរអធិបតេយ្យភាពជាតិជាមួយជំនួយបរទេស ការមិនយកសន្តិភាពរបស់ប្រទេសទៅដោះដូរជាមួយជំនួយ កម្ពុជាត្រូវប្រឹងរស់ដើបឈរឡើងដើម្បីការពារឯករាជ្យ អធិបតេយ្យ និងសន្តិភាពរបស់ប្រទេស» ដែល **សម្ដេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងក្នុងពិធីសំណេះសំណាលជាមួយនិស្សិត និងពលរដ្ឋកម្ពុជា នៅប្រទេសជប៉ុន ក្នុងកំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** អញ្ជើញចូលរួមកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុន លើកទី១០ ចាប់ពីថ្ងៃទី៦-១០ ខែតុលា ឆ្នាំ២០១៨ នាទីក្រុងតូក្យូ ប្រទេសជប៉ុន។

សេចក្ដីថ្លែងរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** គឺជាការបង្ហាញនូវជំហរដ៏មុតមាំប្រកបដោយឧត្តមគតិ និងស្មារតីស្នេហាជាតិ មាតុភូមិដ៏ឧត្តុង្គឧត្តម ដែល **«មិនយកអធិបតេយ្យ ឯករាជ្យជាតិ និងសន្តិភាព ដូរជាមួយជំនួយ និងកម្ពុជាត្រូវមានសិទ្ធិអនុវត្តច្បាប់កម្ពុជា»** ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥២ ដែលចែងច្បាស់ថា «រាជរដ្ឋាភិបាលកម្ពុជា ប្ដេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯករាជ្យជាតិ រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ។

យើងខ្ញុំសូមធ្វើការប្ដេជ្ញាចិត្តយ៉ាងមុតមាំប្រតិបត្តិតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ដោយឥតងាករេក្នុងការអនុវត្តសកម្មភាពចូលរួមការពារឯករាជ្យ អធិបតេយ្យភាព និងសន្តិភាពដ៏មានតម្លៃឱ្យបានស្ថិតស្ថេរគង់វង្ស ជាអមតៈ។

ខ្ញុំបាទ និងថ្នាក់ដឹកនាំ រួមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមវាយតម្លៃខ្ពស់បំផុតចំពោះគោលជំហរ និងឆន្ទៈដ៏មុះមុតខាងលើរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** និងសូមប្រកាសធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះគោលជំហររបស់បុគ្គលមួយចំនួន ដែលមាននិន្នាការផ្ទុយ ដែលព្រមឱនក្បាលដាក់បរទេស ដើម្បីជំនួយជាលេសលូកដៃកក្វរកកាយ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ដែលជារដ្ឋអធិបតេយ្យ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៨

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**